ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងព្រហ្មទណ្ឌលេខ ៥២២
ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៣៩៥
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ៤៨"ឃ"/៦១៩
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

# តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ
# សាលាដំបូងខេត្តសៀមរាប

បើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបនាសាលសវនាការលេខ ៩០២ ។

កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២ និង ៣០ នាទីរសៀល ។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២ និង ៣០ នាទីរសៀល។

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី ក្រុមប្រឹក្សាជំនុំជម្រះ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មីប ។

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះឈ្មោះ ធី ម៉ារីណាត ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៥២២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានជនជាប់ចោទឈ្មោះ [redacted] មីប ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តសៀមរាប ប្រពន្ធឈ្មោះ វួច (ស) មានកូន ០២នាក់ ឪពុកឈ្មោះ គង់ (ស) ម្ដាយឈ្មោះ យឿន (ស) ជាទីតិជន ទោសពីមុន គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៥១ "ច"/២០២១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១



Scanned with CamScanner

ជាប់ចោទពីបទ៖ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ** ប្រព្រឹត្តនៅភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

**ជនរងគ្រោះ៖** ឈ្មោះ [redacted]ាណែត ភេទស្រី អាយុ៨ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប ។

**ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted]ស៊ីណាន ភេទស្រី អាយុ២៨ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប ត្រូវជាម្តាយបង្កើតរបស់ជនរងគ្រោះ ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៦ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

- បានឃើញដីកាដំណោះស្រាយលេខ ២២៧៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

- បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៨៣៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## ឯអង្គហេតុកើតមានដូចតទៅ

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៣ និង ០០នាទី មានជនសង្ស័យឈ្មោះ [redacted] ប៊ឹម បានចេញពីផឹកស្រានៅផ្ទះរបស់ឈ្មោះ ហាន់ ទល់មុខផ្ទះក្មេងស្រីជនរងគ្រោះឈ្មោះ [redacted]ម៉ាណែត អាយុ៨ឆ្នាំ ដែលស្ថិតនៅភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប ពេលនោះជនរងគ្រោះបានរត់ទៅសុំលុយពីជនសង្ស័យចាយ តែជនសង្ស័យមិនបានឱ្យទេ ស្របពេលនោះឪពុកម្តាយជនរងគ្រោះឈ្មោះ [redacted]ម៉ាណែត មិននៅផងជនសង្ស័យបានធ្វើសកម្មភាពលួងលោមជនរងគ្រោះឱ្យស្រាតខោ រួចហើយបានយកប្រដាប់ភេទរបស់ខ្លួនទៅញុលនឹងប្រដាប់ភេទជនរងគ្រោះ ព្រមទាំងបានយកដៃទីស្ទាបអង្អែលប្រដាប់ភេទរបស់ជនរងគ្រោះផងដោយធ្វើសកម្មភាពទាំងអស់នេះនៅចំណុចគុម្ពចេកខាងកើតផ្ទះ បន្ទាប់មកទៅខាងក្រោមផ្ទះ និងបានដកប្រាក់បង្ហាញជនរងគ្រោះដើម្បីឱ្យជនរងគ្រោះទៅយកនៅបង្កន់ រួចខ្លួនបានធ្វើសកម្មភាពស្ទាបអង្អែល និងយកប្រដាប់ភេទរបស់ខ្លួនទៅញុលនឹងប្រដាប់ភេទរបស់ជនរងគ្រោះ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ម៉ឹប បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ថា ខ្លួនបានយកប្រដាប់ភេទរបស់ខ្លួនទៅដាក់លើប្រដាប់ភេទរបស់ឈ្មោះ ម៉ាណែត ចំនួន ០២ដង ក្នុងពេលតែមួយ តែមិនបានចេញទឹក នោះទេ។ នៅថ្ងៃកើតហេតុមិនចាំថ្ងៃ ខែឧសភា ឆ្នាំ២០២១ ម៉ោង ១រសៀល ខ្លួនទៅលេងនៅផ្ទះឈ្មោះ អ៊ុន បន្ទាប់មកឈ្មោះ ម៉ាណែត បបួលខ្លួនទៅបេះផ្លែសេមាន់ ពេលទៅដល់ក្រោយផ្ទះឈ្មោះ អ៊ុន ខ្លួនបានយកប្រដាប់ភេទទៅដាក់លើប្រដាប់ភេទរបស់ឈ្មោះ ម៉ាណែត ដោយមិនបានស្រាតខោនោះទេ មួយសន្ទុះក្រោយមកខ្លួនដើរទៅកន្លែងធ្វើបុណ្យ ហើយដេកនៅកន្លែងធ្វើបុណ្យតែម្តង។ ខ្លួនមិនដឹងថាក្មេងស្រីឈ្មោះ ម៉ាណែត អាយុប៉ុន្មាននោះទេ។ ខ្លួនប្រព្រឹត្តបែបនេះទើបលើកទី១ ហើយក៏មិនបានសម្រេចដែរ ។ ខ្លួនដឹងថាខ្លួនប្រព្រឹត្តបែបនេះគឺមាន ទោស ។ ខ្លួនស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

- ជនរងគ្រោះឈ្មោះ [redacted] ម៉ាណែត បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនមិនចាំថ្ងៃនោះទេ ឈ្មោះ តាម៊ីប បានបបួលខ្លួនទៅគុម្ពចេក ដោយ តាម៊ីប បានឱ្យខ្លួនស្រាតខោ ហើយគាត់បានស្រាតខោរួច យកពងក្ដរបស់គាត់ដាក់ចូលប្រដាប់ភេទរបស់ខ្លួនធ្វើឱ្យខ្លួនឈឺ រួចខ្លួនក៏រត់ទៅក្រោមផ្ទះ ស្រាប់តែឈ្មោះ តាម៊ីប គាត់បានមកតាមខ្លួន ហើយលួងលោមឱ្យខ្លួនស្រាតខោទៀត ដោយសន្យាឱ្យប្រាក់ខ្លួនចំនួន ២,០០០រៀល ក្រោយមកខ្លួនក៏ស្រាតខោ ហើយតាម៊ីប ក៏បានយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួនធ្វើឱ្យខ្លួនឈឺ ហើយតាម៊ីប ក៏ឈប់ទៅ ។ លុះព្រឹកឡើងមិនចាំម៉ោង គាត់បានលួងលោមខ្លួនឱ្យចូលក្នុងបន្ទប់ទឹក ខ្លួនក៏ចូលទៅហើយគាត់ឱ្យខ្លួនស្រាតខោ រួចគាត់ស្រាតខោ និងយកប្រដាប់ភេទរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួនធ្វើឱ្យខ្លួនឈឺហើយខ្លួនក៏រត់ចេញមកក្រៅ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនមិនបាននៅផ្ទះនោះទេ ដោយខ្លួនទៅធ្វើការជាមួយប្ដីនៅសៀមរាប ហើយទុកឱ្យកូនរបស់ខ្លួនឈ្មោះ [redacted] ស៊ីណែត នៅជាមួយយាយនៅផ្ទះ។ លុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] ស្រីឡៀន និងឈ្មោះ [redacted] ផល្លា បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ម៊ីប បានឱ្យកូនរបស់ខ្លួនស្រាតខោ ដោយលើកទី១ នៅគុម្ពចេក និងលើកទី២ នៅក្រោមផ្ទះ និងលើកទី៣ នៅបន្ទប់ទឹក។ ក្រោយមកខ្លួនសួរកូនខ្លួន កូនខ្លួនបានប្រាប់ថា ឈ្មោះ ម៊ីប បានឱ្យលុយចំនួន ២,០០០រៀល តែឱ្យទៅយកនៅបន្ទប់ទឹក ពេលទៅដល់បន្ទប់ទឹកឈ្មោះ ម៊ីប បានឱ្យកូនរបស់ខ្លួនស្រាតខោ ហើយឱ្យគាត់អង្គុយ ហើយឈ្មោះម៊ីប ក៏ស្រាតខោដែរ និងយកប្រដាប់ភេទរបស់គាត់ដាក់ញុលក្នុងប្រដាប់ភេទ កូនស្រីរបស់ខ្លួនហើយខ្លួនសួរគាត់ថាហេតុអ្វីកូនមិនរត់ចេញ គាត់ឆ្លើយថាឈ្មោះ ម៊ីប បានចាប់ដៃគាត់មិនឱ្យចេញ លុះពេលគាត់ឈឺ ទើបឈ្មោះ ម៊ីប លែងដៃគាត់ហើយគាត់ក៏រត់ចេញ ។ បន្ទាប់មកខ្លួនបាននាំកូនទៅពិនិត្យប្រដាប់ភេទអត់មានក្រហមទេ ប៉ុន្តែកូនស្រីខ្លួនប្រាប់ខ្លួនថាឈឺ ហើយកូនស្រីខ្លួនមានស្មារតីធម្មតា ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីឡៀន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនអង្គុយលេងនៅនឹងផ្ទះរបស់ខ្លួន ហើយខ្លួនឃើញ តាម៊ីប ចេញពីគុម្ពចេក ហើយខ្លួនឃើញឈ្មោះ [redacted] ស៊ីណែត អង្គុយសរសេរអក្សរ នៅក្រោមផ្ទះ រួចឃើញឈ្មោះ ម៊ីប ចាប់ប្រដាប់ភេទរបស់ឈ្មោះ ធី ស៊ីណែត រួចគាត់នាំទៅម្លាងម៉ូតូ ហើយកំបាំងនឹងស្បៃ ខ្លួនមើលឃើញ តាម៊ីប ស្រាតខោ ស្រីណែត បន្ទាប់មកឃើញ ស្រីណែត រត់ទៅក្នុងបន្ទប់ទឹក ហើយឈ្មោះ ម៊ីប រត់ទៅតាមក្រោយ បន្ទាប់មកខ្លួនមិនដឹងអ្វីទៀតនោះទេ។ ពេលស្រីណែត រត់ចូលបន្ទប់ទឹក ស្រីណែត នៅស្លៀកខោ ហើយមួយសន្ទុះធំ ឃើញតាម៊ីប ចេញពីបន្ទប់ទឹកមកវិញ ហើយឃើញស្រីណែត មកតាមក្រោយដោយមិនមានយំនោះទេគឺធម្មតា ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ផល្លា បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនរត់លេងនៅក្បែរផ្ទះស្រីណែត ស្រាប់តែឃើញ តាម៊ីប ទៅផ្ទះ ស្រីណែត ពេលនោះខ្លួនរត់ទៅផ្ទះ ស្រីឡៀន ហើយលបមើលម្ដាងរបង ស្រាប់តែឃើញ តាម៊ីប ចាប់ស្មាឱ្យស្រីណែត ស្រាតខោ ផ្ដេកព្រុសពេលនោះស្រីណែត ឃើញខ្លួនក៏រត់ទៅបន្ទប់ទឹក ស្រាប់តែ តាម៊ីប ទៅតាម មួយសន្ទុះធំ តាម៊ីប ដើរចេញមកក្រៅ ហើយស្រីណែត ដើរចេញតាមក្រោយដោយធ្វើមុខធម្មតា។

- លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយឆ្លងកាត់សវនាការ និងក្រោយពីបានពិនិត្យទៅលើសំណុំរឿងនេះមក ឃើញថា កាលពីខែឧសភា ឆ្នាំ២០២១ កន្លងទៅកូនក្ដីខ្លួន ត្រូវបានជនជាប់ចោទឈ្មោះ [redacted] ម៊ីប អាយុ៥៦ឆ្នាំ បានរំលោភសេពសន្ថវៈ ចំនួន០៣ដង លើកទី១ នៅគុម្ពចេក លើកទី២ នៅក្រោមផ្ទះ និងលើកទី៣ នៅក្នុងបន្ទប់ទឹក ហើយជនជាប់ចោទបានប្រើប្រាស់ធម្មៀ

បាយទាញយកប្រយោជន៍ពីសេចក្តីទុកចិត្តរបស់កុមារីដែលជាជនរងគ្រោះ ដោយលួងលោមថានឹងឱ្យលុយទិញនំ ចំនួន ២,០០០រៀល និងបានបង្ខិតបង្ខំដោយធ្វើការចាប់ដៃ មិនឱ្យកូនក្តីខ្លួនរត់គេចបាន នៅពេល ដែលកូនក្តីខ្លួនឈឺចាប់ខ្លាំង ជនជាប់ចោទខ្លាចជនរងគ្រោះស្រែកធ្វើឱ្យអ្នកជិតខាងលឺ ក៏បណ្តោយឱ្យកូនក្តីខ្លួនរត់ចេញពីទីតាំងកើតហេតុប៉ុន្តែជនជាប់ចោទមិនបានបញ្ឈប់អំពើស្មោកគ្រោក ដែលសង្គមស្អប់ខ្ពើមនេះទេនៅតែបន្តប្រព្រឹត្តនៅទីតាំងផ្សេងប្រើការលួងលោមថានឹងឱ្យលុយនេះដដែល ។ អំពើដែលជនជាប់ចោទបានប្រព្រឹត្តនេះមានចែងក្នុងមាត្រា២៣៩នៃក្រមព្រហ្មទណ្ឌ ម្យ៉ាងទៀតអំពើរបស់ជនចាប់ចោទមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ហើយជនរងគ្រោះជាអនីតិជនមានអាយុទើបតែ៨ឆ្នាំ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមមាត្រា២៤១នៃក្រមព្រហ្មទណ្ឌ ឯសំណងរដ្ឋប្បវេណីស្នើសុំពិចារណាតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

- លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងកាត់ការដេញដោល កូនក្តីខ្លួនបានទទួលស្គាល់នូវកំហុស ដោយសារការគិតមិនបានវែងឆ្ងាយខ្វះសមត្ថភាពក្នុងការយល់ដឹងពីច្បាប់និងមិនបានរៀនសូត្របានជ្រៅជ្រះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានធ្វើការពិភាក្សាដេញដោលនាពេលសវនាការរួចមក តាមចម្លើយជនរងគ្រោះ និងចម្លើយសាក្សី ហើយជនជាប់ចោទបានឆ្លើយសារភាពនូវទង្វើប្រព្រឹត្តរបស់ខ្លួន ដូចនេះតំណាងអយ្យការសុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- សំណូមពរសម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំតុលាការបន្ធូរបន្ថយទោសទោស ។

- សំណូមពរសម្តីចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖ ស្នើសុំតុលាការអនុវត្តទោសតាមច្បាប់ និងសុំទាមទារសំណងជម្ងឺចិត្តចំនួន ៨០០(ប្រាំបីរយ)ដុល្លារអាមេរិក ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យលើឯកសារភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

- កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៣ និង ០០នាទី មានជនសង្ស័យឈ្មោះ [redacted] ម៉ីប បានចេញពីផឹកស្រានៅផ្ទះរបស់ឈ្មោះ ហាន់ ទល់មុខផ្ទះក្មេងស្រីជនរងគ្រោះឈ្មោះ [redacted] ម៉ាណែត អាយុ៨ឆ្នាំ ដែលស្ថិតនៅភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប ពេលនោះជនរងគ្រោះបានរត់ទៅសុំលុយពីជនសង្ស័យថាយ តែជនសង្ស័យមិនបានឱ្យទេ ស្របពេលនោះឪពុកម្តាយជនរងគ្រោះឈ្មោះ [redacted] ម៉ាណែត មិននៅផងជនសង្ស័យបានធ្វើសកម្មភាពលួងលោមជនរងគ្រោះឱ្យស្រាតខោ រួចហើយបានយកប្រដាប់ភេទរបស់

ខ្លួនទៅញុលនឹងប្រដាប់ភេទជនរងគ្រោះ ព្រមទាំងបានយកដៃទីស្ទាបអង្អែលប្រដាប់ភេទរបស់ជនរងគ្រោះផង ដោយធ្វើសកម្មភាពទាំងអស់នេះនៅចំណុចគុម្ពចេកខាងកើតផ្ទះ បន្ទាប់មកទៅខាងក្រោមផ្ទះ និងបានដកប្រាក់បង្ហាញជនរងគ្រោះដើម្បីឱ្យជនរងគ្រោះទៅយកនៅបង្គន់ រួចខ្លួនបានធ្វើសកម្មភាពស្ទាបអង្អែល និងយកប្រដាប់ភេទរបស់ខ្លួនទៅញុលនឹងប្រដាប់ភេទរបស់ជនរងគ្រោះ ។

- ជនជាប់ចោទឈ្មោះ[redacted]មីប ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ៖រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ ប្រព្រឹត្តនៅ ភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

- តាមចម្លើយរបស់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សីបំភ្លឺ និងចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ និងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារនានាដែលមាននៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទគឺពិតជាបានធ្វើសកម្មភាពរំលោភទៅលើជនរងគ្រោះ ប្រាកដមែន ។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះថា៖ ក្រោយឆ្លងកាត់សវនាការ និងក្រោយពីបានពិនិត្យទៅលើសំណុំរឿងនេះមកឃើញថា កាលពីខែឧសភា ឆ្នាំ២០២១ កន្លងទៅកូនក្តីខ្ញុំត្រូវបានជនជាប់ចោទឈ្មោះ [redacted] មីប អាយុ៥៦ឆ្នាំ បានរំលោភសេពសន្ថវៈ ចំនួន០៣ដង លើកទី១ នៅគុម្ពចេក លើកទី២ នៅក្រោមផ្ទះនិងលើកទី៣ នៅក្នុងបន្ទប់ទឹកហើយជនជាប់ចោទបានប្រើប្រាស់ឧបាយទាញយកប្រយោជន៍ពីសេចក្តីទុកចិត្តរបស់កុមារីដែលជាជនរងគ្រោះ ដោយលួងលោមថានឹងឱ្យលុយទិញនំ ចំនួន ២,០០០រៀល និងបានបង្ខិតបង្ខំដោយធ្វើការចាប់ដៃមិនឱ្យកូនក្តីខ្ញុំរត់គេចបាននៅពេលដែលកូនក្តីខ្ញុំឈឺចាប់ខ្លាំង ជនជាប់ចោទខ្លាចជនរងគ្រោះស្រែកធ្វើឱ្យអ្នកជិតខាងលឺ ក៏បណ្តោយឱ្យកូនក្តីខ្ញុំរត់ ចេញពីទីតាំងកើតហេតុប៉ុន្តែជនជាប់ចោទមិនបានបញ្ឈប់អំពើស្មោកគ្រោក ដែលសង្គមស្អប់ខ្ពើមនេះទេនៅតែ បន្តប្រព្រឹត្តនៅទីតាំងផ្សេងប្រើការលួងលោមថានឹងឱ្យលុយនេះដដែល ។ អំពើដែលជនជាប់ចោទបានប្រព្រឹត្ត នេះមានចែងក្នុងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ម្យ៉ាងទៀតអំពើរបស់ជនចាប់ចោទមានធាតុផ្សំបទល្មើសគ្រប់ គ្រាន់ ហើយជនរងគ្រោះជាអនីតិជនមានអាយុទើបតែ៨ឆ្នាំ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ឯសំណងរដ្ឋប្បវេណីស្នើសុំពិចារណាតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ថា ឆ្លងកាត់ការដេញដោល កូនក្តីខ្ញុំបានទទួលស្គាល់នូវកំហុស ដោយសារការគិតមិនបានវែងឆ្ងាយខ្វះសមត្ថភាពក្នុងការយល់ដឹងពីច្បាប់ និងមិនបានរៀនសូត្របានជ្រៅជ្រះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំ។ គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ថា ក្រោយពីបានធ្វើការពិភាក្សាដេញដោលនាពេលសវនាការរួចមក តាមចម្លើយជនរងគ្រោះ និងចម្លើយសាក្សី ហើយជនជាប់ចោទបានឆ្លើយសារភាពនូវទង្វើប្រព្រឹត្តរបស់ខ្លួន ដូចនេះតំណាងអយ្យការសុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការពិចារណាតាមច្បាប់ ។

- ជនជាប់ចោទ អាចយល់ដឹងគ្រប់គ្រាន់ និងមានស្មារតីរឹងមាំអាចដឹងចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដូច្នេះអាចទទួលការចោទប្រកាន់ និងអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។

- អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ កិត្តិយសអ្នកដទៃ ប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាពិសេសខុសនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មឹប ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុំណាន បានទាមទារសំណងជម្ងឺចិត្តចំនួន ៨០០(ប្រាំបីរយ) ដុល្លារអាមេរិក ។ គប្បីតុលាការលើកយកមកពិចារណាតាមស្ថានភាពជាក់ស្តែង ។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសលើឈ្មោះ [redacted] មឹប ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៨(ប្រាំបី)ឆ្នាំ ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឱ្យឈ្មោះ [redacted] មឹប សងសំណងជម្ងឺចិត្តចំនួន ៨០០(ប្រាំបីរយ)ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុំណាន ។ ការទាមទារលើសពីនេះបដិសេធចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មឹប ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុំណាន និងជនរងគ្រោះឈ្មោះ [redacted] ម៉ាណែត និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ "ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់" ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]